# ជំពូកទី២

# ក្របខ័ណ្ឌច្បាប់

Draft

# ជំពូកទី ២
# ក្របខ័ណ្ឌច្បាប់

## ២.១ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

ច្បាប់នេះរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ នាសម័យប្រជុំលើកទី៧ នីតិកាលទី១ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម ១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ។ ច្បាប់បរិស្ថាននេះមានគោលដៅដូចតទៅ:

- ការពារ លើកកម្ពស់គុណភាពបរិស្ថាន និងសុខភាពពលរដ្ឋដោយធ្វើការទប់ស្កាត់ កាត់បន្ថយ និងត្រួតពិនិត្យលើការបំពុល ។
- វាយតំលៃហេតុប៉ះពាល់បរិស្ថានមុននឹងចេញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ចំពោះរាល់គំរោងដែលបានស្នើឡើង ។
- ធានាឱ្យមានការអភិរក្ស អភិវឌ្ឍន៍ គ្រប់គ្រង និងប្រើប្រាស់ដោយសមហេតុផល និងប្រកបដោយនិរន្តរភាពនូវធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា ។
- លើកទឹកចិត្ត និងផ្តល់លទ្ធភាពឱ្យសាធារណៈជនចូលរួមក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។
- បង្ក្រាបរាល់អំពើទាំងឡាយណាដែលធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន។ ទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិ ច្បាប់នេះបានតម្រូវឱ្យបណ្តាក្រុមហ៊ុនទាំងអស់ត្រូវធ្វើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ។ ផ្អែកលើច្បាប់នេះ បានចែងក្នុងមាត្រាមួយចំនួនដូចខាងក្រោម :

**មាត្រា៦:** ចែងថា "ការវាយតំលៃហេតុប៉ះពាល់បរិស្ថានត្រូវអនុវត្តលើរាល់គំរោង និងសកម្មភាពរបស់ឯកជន ឬសាធារណៈ ហើយត្រូវបានពិនិត្យ និងវាយតំលៃដោយក្រសួងបរិស្ថានមុនដាក់ជូនរាជរដ្ឋាភិបាលសម្រេច។ ការវាយតំលៃនេះក៏ត្រូវបានអនុវត្តផងដែរចំពោះសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ ហើយដែលពុំទាន់បានវាយតំលៃហេតុ-ប៉ះពាល់បរិស្ថាននៅឡើយ។ បែបបទនៃកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងបរិស្ថាន។ ប្រភេទ និងទំហំគំរោង និងសកម្មភាពដែលស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការទាំងឯកជន និងសាធារណៈដែលត្រូវមានការវាយតំលៃហេតុប៉ះពាល់បរិស្ថាននោះ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងបរិស្ថាន"។

**មាត្រា៧:** បានចែងថា "ចំពោះរាល់ពាក្យសុំធ្វើគំរោងវិនិយោគ និងរាល់គំរោងដែលរដ្ឋស្នើឡើងត្រូវមានការវាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ដូចមានចែងក្នុងមាត្រា៦ នៃច្បាប់នេះ។ ក្រសួងបរិស្ថានត្រូវពិនិត្យ

និងផ្តល់យោបល់លើការវាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញទៅអង្គការមានសមត្ថកិច្ចក្នុងរយៈពេលដូចបានកំណត់ក្នុងច្បាប់ស្តីពីការវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា"។

លើសពីនេះទៅទៀត ច្បាប់នេះបានកំណត់ផងដែរ អំពីការគ្រប់គ្រងធនធានធម្មជាតិដែលមានចែងក្នុងមាត្រា ៨ មាត្រា ៩ មាត្រា ១០ និងមាត្រា ១១ ។ យើងនឹងលើកយកមាត្រា ៨ មកបង្ហាញដូចខាងក្រោមនេះ :

**មាត្រា៨:** បានចែងថា "ធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា ដែលមានជាអាទិ៍ ដីធ្លី ទឹក អាកាស ខ្យល់ ភូគព្ភសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាត ឧស្ម័ន ថ្ម ខ្សាច់ ត្បូងថ្ម ព្រៃឈើ និងអនុផលព្រៃឈើ ពពួកសត្វព្រៃ មច្ឆាជាតិ ធនធានជលផល ត្រូវបានអភិរក្ស អភិវឌ្ឍន៍ គ្រប់គ្រង និងប្រើប្រាស់ដោយសមហេតុផល និងប្រកបដោយភាពស្ថិតស្ថេរ។

## ២.២ ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ

ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៦ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមទម្រង់ និងគតិយុទ្ធនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៥ នីតិកាលទី ១។

នៅជំពូកទី ៦ ស្តីពី**សម្បទានិក និងម្ចាស់កម្មសិទ្ធិដី** ត្រង់មាត្រាទី ២៥ បានចែងថា សម្បទានិកដែលមានអាជ្ញាប័ណ្ណធនធានរ៉ែ ត្រូវសងទៅម្ចាស់កម្មសិទ្ធិដីទាំងក្នុង និងក្រៅតំបន់អាជ្ញាប័ណ្ណធនធានរ៉ែ ចំពោះការខូចខាតទាំងឡាយដែលបណ្តាលមកពីប្រតិបត្តិការអាជីវកម្មធនធានរ៉ែរបស់ខ្លួនដោយមិនគិតថា ការខូចខាតនោះជាឧបទ្ទវហេតុ ឬជាការដឹងមុន។

ក្នុងករណីការខូចខាតណាដែលបណ្តាលមកពីប្រតិបត្តិការអាជីវកម្មធនធានរ៉ែរបស់សម្បទានិក ចាប់ពីពីររូបឡើងទៅ សម្បទានិកទាំងនោះត្រូវរួមគ្នាសងទៅតាមការខូចខាត។ សំណងទាំងនោះត្រូវអនុវត្តដូចខាងក្រោមៈ

- ប្រសិនបើជាតំបន់ប្រតិបត្តិការធនធានរ៉ែ ដែលមានកំណត់នៅក្នុងអាជ្ញាប័ណ្ណធនធានរ៉ែ ប៉ះពាល់លើដីកម្មសិទ្ធិម្ចាស់ដី ត្រូវអនុញ្ញាតឱ្យសម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណធនធានរ៉ែ ធ្វើប្រតិបត្តិការធនធានរ៉ែនៅលើដីនោះ ដោយមានការព្រមព្រៀងគ្នាទៅវិញទៅមកជាមុន ដែលក្នុងនោះម្ចាស់ដីត្រូវទទួលបានសំណងសមរម្យ និងយុត្តិធម៌។

- សំណងនោះត្រូវសងតាមពេលវេលា ឬសងផ្តាច់តែម្តង តាមការព្រមព្រៀងរវាងម្ចាស់ដី និងសម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណធនធានរ៉ែ។

- ក្នុងករណីម្ចាស់ដី និងសម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណធនធានរ៉ែ មិនអាចស្រុះស្រួលគ្នាលើសំណងបានទេនោះ រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែត្រូវសម្រួលដោះស្រាយ បើមិនបានសម្រេចទេ ត្រូវធ្វើសំណើទៅរាជរដ្ឋាភិបាល ដើម្បីបង្កើតគណៈកម្មាការចម្រុះមួយសម្រាប់ដោះស្រាយករណីនេះ។

Draft

- ក្នុងករណីដែលភាគីទាំងអស់មិនយល់ព្រមតាមដំណោះស្រាយរបស់គណៈកម្មាការចម្រុះទេនោះ សេចក្តីសំរេចជាសមត្ថកិច្ចរបស់តុលាការ ។

**មាត្រា ២១** សម្បទានិក ឬអ្នកចុះកិច្ចសន្យាបន្តនីមួយៗ ត្រូវទទួលខុសត្រូវលើការដឹកនាំប្រតិបត្តិការស្វែងរុករក និងធ្វើអាជីវកម្មធនធានរ៉ែ នឹងត្រូវអនុវត្តទៅតាមការកំណត់ដូចខាងក្រោមនេះ :

១- ដំណើរការប្រតិបត្តិការឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធិភាពតាមលក្ខណៈបច្ចេកទេស និងហិរញ្ញវត្ថុ ដែលនឹងលំអិតក្នុងកម្មវិធីការងារស្វែងរុករក ឬការសិក្សាអំពីសមិទ្ធិលទ្ធភាពអណ្តូងរ៉ែ ។

២- ការពារបរិស្ថាន ដូចមានលំអិតក្នុងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ការសិក្សាវាយតំលៃហេះប៉ះពាល់បរិស្ថាន ផែនការគ្រប់គ្រងបរិស្ថាន ផែនការលុបអណ្តូងរ៉ែ និងការធានាផ្នែកហិរញ្ញវត្ថុ ។

៣- ធានាការការពារសុខភាព និងសុវត្ថិភាពពលករដែលនឹងលំអិតក្នុងកម្មវិធីផែនការអណ្តូងរ៉ែ កម្មវិធីសុខភាព និងសុវត្ថិភាពក្នុងអណ្តូងរ៉ែរាប់បញ្ចូលទាំងការការពារគ្រោះថ្នាក់ បែបបទរាយការណ៍ស្តីពីគ្រោះថ្នាក់នេះ ។

៤- ការពារសុវត្ថិភាពដល់សាធារណជននៅក្នុង និងជុំវិញតំបន់អណ្តូងរ៉ែ ដែលនឹងលំអិតក្នុងផែនការអណ្តូងរ៉ែ ។

៥- ធ្វើការអប់រំ បណ្តុះបណ្តាល និងផ្តល់ការងារដល់ប្រជាពលរដ្ឋខ្មែរ ដែលនឹងលំអិតក្នុងកម្មវិធីផ្តល់ការងារ អប់រំ បណ្តុះបណ្តាល ។

៦- ប្រើប្រាស់ឱ្យអស់លទ្ធភាពនូវទំនិញ និងសេវាកម្មក្នុងព្រះរាជាណាចក្រកម្ពុជា នៅតាមកន្លែង និងពេលវេលាសមស្រប ។

## ២.៣ ច្បាប់ភូមិបាល

ច្បាប់ភូមិបាល ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០១ នាសម័យប្រជុំពេញអង្គលើកទី៦ នីតិកាលទី២ ហើយដែលព្រឹទ្ធសភាពបានអនុម័តយល់ព្រមទាំងស្រុងកាលពីថ្ងៃទី ១៣ ខែសីហា ឆ្នាំ២០០១ នាសម័យប្រជុំពេញអង្គលើកទី៥ នីតិកាលទី១ ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨១០/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ។

ច្បាប់នេះមានគោលដៅកំណត់អំពីរបបកម្មសិទ្ធិលើអចលនវត្ថុទាំងឡាយក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងធានាការពារសិទ្ធិនៃកម្មសិទ្ធិ និងសិទ្ធិផ្សេងទៀតលើអចលនវត្ថុស្របតាមបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជា ។

តាមច្បាប់នេះ នៅក្នុង **មាត្រា២** បានបង្ហាញនូវន័យនៃពាក្យថា "**អចលនវត្ថុ**"ថា "អចលនវត្ថុតាមន័យនៃច្បាប់នេះមានអចលនវត្ថុពីកំណើត អចលនវត្ថុពីភ័ព្វវាសនា និងអចលនវត្ថុតាមការកំណត់របស់ច្បាប់" ។ ក្នុងនោះយើងលើក

យកប្រភេទនៃអចលនវត្ថុពីកំណើត និងអចលនវត្ថុពីភព្វវាសនា មកបង្ហាញ ព្រោះវាមានទំនាក់ទំនងនឹងកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ជាងគេ :

- អចលនវត្ថុពីកំណើតមាន ដីធម្មជាតិដូចជា ដីព្រៃឈើ ដីកាប់រាន ដីដាំដុះ ដីទុកទំនេរ ឬមិនអាចដាំដុះ ដីលិចទឹក ដោយទឹកនៅនឹង ឬទឹកហូរ និងសំណង់ ឬ ការរៀបចំទាំងឡាយដែលស្ថិតនៅជាប់មួយកន្លែង កើតឡើងដោយអំពើរបស់មនុស្ស ហើយមិនអាចរំកិល ឬផ្លាស់ប្តូរកន្លែងបាន ។
- អចលនវត្ថុពីភព្វវាសនា មានវត្ថុដែលជាប់នឹងដី ឬបញ្ចូលជាមួយសំណង់ទាំងឡាយ ដែលមិនអាចបំបែកចេញបានដោយមិនធ្វើឱ្យខូចខាត ឬមិនដូរសភាពដើមដូចជា ដើមឈើ ឧបករណ៍តែងលំអរជាដើម ។

ក្រៅពីមាត្រានេះ យើងឃើញមានមាត្រាមួយចំនួនទៀត ដែលសំខាន់ខ្លាំងក្នុងកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និសង្គម រួមមាន មាត្រា ៥ មាត្រា ៦ មាត្រា ១៨ មាត្រា ២៥ និង មាត្រា ២៨ ។ សេចក្តីសង្ខេបនៃមាត្រាទាំងនេះមានដូចខាងក្រោម:

**មាត្រា៥:** គ្មានបុគ្គលណាមួយត្រូវបានគេដកហូតកម្មសិទ្ធិរបស់ខ្លួនបានទេ ប្រសិនបើការដកហូតនេះមិនមែនដើម្បីប្រយោជន៍សាធារណៈ ។ ការដកហូតត្រូវធ្វើទៅតាមទម្រង់ និងនីតិវិធីបញ្ញត្តិដោយច្បាប់ និងបទបញ្ជា បន្ទាប់ពីបានផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌ ។

**មាត្រា៦:** មានតែភោគៈត្រឹមត្រូវតាមច្បាប់ប៉ុណ្ណោះ ដែលអាចនាំឱ្យបានកម្មសិទ្ធិ ។ រដ្ឋក៏អាចផ្តល់កម្មសិទ្ធិនៃទ្រព្យជាអចលនវត្ថុ ដែលជារបស់រដ្ឋក្នុងព្រំដែនជាក់លាក់ដែលបានកំណត់ដោយច្បាប់នេះដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរ ។

**មាត្រា១៨:** ត្រូវទុកជាមោឃៈ និងគ្មានអានុភាព ហើយមិនអាចត្រូវបានធ្វើនិយ័តកម្ម ទោះតាមរូបភាពណាក៏ដោយនូវ :

- រាល់ការចូលកាន់កាប់ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ និងរាល់ការបំប្លែងការកាន់កាប់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋទៅជាសិទ្ធិកម្មសិទ្ធិ ទោះបីការកាន់កាប់ និងការបំប្លែងនេះកើតមាននៅពេលណាក៏ដោយ ដែលមិនស្របតាមលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីដែលបានកំណត់កន្លងមក ។
- រាល់ការចូលកាន់កាប់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ទោះជាតាមរូបភាពណាក៏ដោយ ដែលបានកើតឡើងក្រោយច្បាប់នេះចូលជាធរមាន ។

**មាត្រា ១៩ :** បុគ្គលទាំងឡាយដែលមានប័ណ្ណ ឬមានស្ថានភាពជាក់ស្តែងឋិតនៅក្រោមឥទ្ធិពលនៃមាត្រា ១៨ នៃច្បាប់នេះ មិនអាចទាមទារសំណងទូទាត់ ឬសោហ៊ុយសម្រាប់ការថែទាំ ឬការរៀបចំដែលបានធ្វើនៅលើអចលនវត្ថុដែលបានកាន់កាប់ដោយខុសច្បាប់បានឡើយ ។



Draft

មាត្រា២៥: ដីសហគមន៍ជនជាតិដើមភាគតិច គឺជាដីទាំងអស់ដែលសហគមន៍បានរៀបចំនិវេសនដ្ឋាន និងប្រកបរបរកសិកម្មប្រពៃណី។ ដីសហគមន៍ជនជាតិដើមភាគតិច មិនមែនមានតែដីដែលបានដាំដុះជាក់ស្តែងនោះទេ ប៉ុន្តែមានដីបំរុងចាំបាច់ក្នុងការដូរវេនដំណាំថែមទៀត ដែលតម្រូវទៅតាមរបៀបទាញយកផលដែលធ្លាប់ធ្វើកន្លងមក ហើយត្រូវបានទទួលស្គាល់ដោយអាជ្ញាធររដ្ឋបាល។ ការវាស់វែង និងការកំណត់ព្រំប្រទល់នៃអចលនវត្ថុរបស់សហគមន៍ទាំងនោះត្រូវកំណត់ទៅតាមស្ថានភាពជាក់ស្តែងដូចដែលបានអះអាងដោយសហគមន៍ ដោយមានការព្រមព្រៀងពីអ្នកជិតខាង និងដែលបានកំណត់តាមនីតិវិធីក្នុងមាតិកាទី ៦ នៃច្បាប់នេះ និងអនុក្រឹត្យពាក់ព័ន្ធ។

មាត្រា២៨: គ្មានអាជ្ញាធរណាមួយក្រៅពីសហគមន៍ អាចទទួលបានសិទ្ធិលើអចលនវត្ថុរបស់ជនជាតិដើមភាគតិចបានឡើយ។

យោងតាមច្បាប់ភូមិបាលដែលបានដកស្រង់មកបង្ហាញនេះ ចង់មានន័យថា ប្រជាជនដែលមានសញ្ជាតិខ្មែរគ្រប់រូបអាចមានកម្មសិទ្ធិលើដីធ្លី ដែលមានការទទួលស្គាល់ដោយស្របច្បាប់ពីអាជ្ញាធររដ្ឋបាល។ ហើយគ្មានកម្មសិទ្ធិមួយណាត្រូវបានគេដកហូតដោយមិនស្ថិតនៅក្នុងហេតុផលប្រយោជន៍សាធារណៈនោះទេ ហើយប្រសិនបើមានការដកហូតក្នុងប្រយោជន៍សាធារណៈក៏តម្រូវឱ្យមានជាសំណងត្រឹមត្រូវតាមច្បាប់។ ករណីខ្លះ ការដកហូតនឹងមិនត្រូវបានចេញជាសំណងឱ្យនោះទេ ប្រសិនបើកម្មសិទ្ធិនោះមិនត្រូវបានទទួលស្គាល់តាមច្បាប់ដែលបានចែងក្នុងមាត្រា ១៨ នៃច្បាប់នេះ។

ចំពោះការកាន់កាប់ដីរបស់សហគមន៍ជនជាតិដើម គ្រប់រូបភាព មិនមែនត្រឹមតែដីលំនៅដ្ឋាន ដីធ្វើស្រែ-ចំការតាមប្រពៃណី តែអាចជាដីបំរុងទុកផ្សេងៗ ក៏នឹងត្រូវបានទទួលស្គាល់ថាជាកម្មសិទ្ធិស្របច្បាប់របស់សហគមន៍ជនជាតិដើមដែរ ប្រសិនណាមានការទទួលស្គាល់ដោយអាជ្ញាធររដ្ឋបាល (*សេចក្តីលំអិតនៃច្បាប់ ស្ថិតនៅក្នុងសៀវភៅស្តីពី "ច្បាប់ភូមិបាល"*)។

## ២.៤ ច្បាប់ស្តីពីព្រៃឈើ

ច្បាប់ស្តីពីព្រៃឈើ ត្រូវបានរដ្ឋសភាអនុម័តកាលពីថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០២ នាសម័យប្រជុំពេញអង្គលើកទី ៨ នីតិកាលទី២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របកាលពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០២ និងបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២។

ច្បាប់នេះមានគោលបំណង ធានានូវការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ដើម្បីផលប្រយោជន៍សង្គម សេដ្ឋកិច្ច និងបរិស្ថាន រួមទាំងការអភិរក្សជីវៈចម្រុះ និងមរតកវប្បធម៌ ហើយមានវិសាលភាពអនុវត្តលើរាល់ព្រៃឈើទាំងអស់ ទោះជាប្រភេទព្រៃនោះកើតឡើងដោយធម្មជាតិក្តី ឬដោយដាំក្តី។

ក្នុងច្បាប់នេះ មានមាត្រាមួយចំនួនពាក់ព័ន្ធខ្លាំងជាមួយនឹងកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ដែលរួមមាន:



Draft

**មាត្រា៤:** បានចែងថា "រាល់ការសម្រេចរបស់រាជរដ្ឋាភិបាលដែលមានសក្តានុពលភាពចំពោះផលប៉ះពាល់ធ្ងន់ធ្ងរទៅលើប្រជាពលរដ្ឋទូទៅ លើជីវភាពសហគមន៍មូលដ្ឋាន និងលើធនធានព្រៃឈើនៃព្រះរាជាណាចក្រកម្ពុជា ត្រូវមានការចូលរួមជាសាធារណៈ។ សកម្មភាពចម្បង១ពាក់ព័ន្ធទៅនឹងប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើ ដែលអាចបណ្តាលឱ្យមានផលប៉ះពាល់អាក្រក់ដល់សង្គម និងបរិស្ថាន ចាំបាច់ត្រូវមានការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គម ដោយផ្អែកតាមក្រមបច្ចេកទេសគ្រប់គ្រងព្រៃឈើកម្ពុជា និងស្របតាមច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។ ឯកសារនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមត្រូវផ្តល់ជូនសម្រាប់ការចូលរួមផ្តល់មតិជាសាធារណៈបាន។ រាល់ការសំរេចចុងក្រោយលើរាល់សកម្មភាពចម្បង១ពាក់ព័ន្ធទៅនឹងប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើ រាជរដ្ឋាភិបាលត្រូវពិចារណាលើអនុសាសន៍ចុងក្រោយនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គម។ ការសំរេចចុងក្រោយណាមួយក្រោមមាត្រានេះ រាជរដ្ឋាភិបាលអាចធ្វើការជូនដំណឹងជាសាធារណៈ"។

**មាត្រា១០:** ត្រង់ចំនុចស្តីពីព្រៃបម្រុងទុកអចិន្ត្រៃយ៍ លេខ ២ បានចែងថាៈ

ព្រៃការពារត្រូវបានរក្សាទុកជាចម្បង ដើម្បីការពារប្រព័ន្ធមជ្ឈដ្ឋាន និងធម្មជាតិ។ ព្រៃការពារមានជាអាទិ៍ :

- ព្រៃបម្រុងទុកសម្រាប់ប្រព័ន្ធមជ្ឈដ្ឋានពិសេស
- ព្រៃសម្រាប់សិក្សាស្រាវជ្រាវ
- ព្រៃនិយតកម្មប្រភពទឹក
- ព្រៃការពារទីជំរាល
- ព្រៃលំហែកំសាន្ត
- សួនរុក្ខជាតិ
- ព្រៃជំនឿសាសនា។

ព្រៃការពារនេះអាចអនុញ្ញាតឱ្យប្រមូលផល អនុផលព្រៃឈើជាលក្ខណៈប្រពៃណី ដែលមានផលប៉ះពាល់ទាបដោយសហគមន៍មូលដ្ឋាន។

**មាត្រា១៥:** ព្រៃសម្បទានិកមានសិទ្ធិដំណើរការគ្រប់គ្រង និងប្រមូលផល អនុផលព្រៃឈើនៅក្នុងដែនព្រៃសម្បទានរបស់ខ្លួន ដោយធានាថាប្រតិបត្តិការទាំងនេះនឹងមិនប៉ះពាល់ដល់ៈ

១- សិទ្ធិប្រើប្រាស់ជាប្រពៃណី ដែលអនុវត្តនៅលើដីកម្មសិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិច ដែលបានចុះបញ្ជីការដោយរដ្ឋស្របតាមច្បាប់ភូមិបាល

២- សិទ្ធិចេញ-ចូល និងសិទ្ធិប្រើប្រាស់ជាប្រពៃណី អនុវត្តដោយសហគមន៍ដែលមានទីតាំងក្នុង ឬក្បែរព្រៃសម្បទាន។

Draft

តាមរយៈអត្ថន័យនៃច្បាប់ ដែលបានដកស្រង់ខាងលើនេះបង្ហាញថា ការផ្តល់ដីសម្បទានដែលពាក់ព័ន្ធនឹងព្រៃឈើក្នុងតំបន់ទាមទារនូវការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន ដោយមានការចូលរួមពីសាធារណៈជន។ ក្នុងនោះដែរ ព្រៃឈើមួយចំនួនត្រូវធ្វើការរក្សាទុក និងអនុញ្ញាតដល់ប្រជាជនក្នុងតំបន់ប្រើប្រាស់តាមបែបប្រពៃណី ដែលធ្លាប់បានធ្វើកន្លងមក ដោយគ្មានការហាមឃាត់ពីសំណាក់ក្រុមហ៊ុនដីសម្បទានិក។

## ២.៥ ច្បាប់ជលផល

ច្បាប់ស្តីពីជលផល ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភា លើកទី ៤ នីតិកាលទី ៣ និងត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ មានគោលបំណងធានានូវការគ្រប់គ្រងជលផល និងធនធានជលផល ជំរុញកិច្ចអភិវឌ្ឍវារីវប្បកម្ម ផលិតកម្ម និងការកែច្នៃលើកស្ទួយជីវភាពរស់នៅរបស់ពលរដ្ឋក្នុងសហគមន៍មូលដ្ឋាន ដើម្បីផលប្រយោជន៍សង្គម សេដ្ឋកិច្ច និងបរិស្ថាន រួមទាំងការអភិរក្សជីវចំរុះផង ទាំងមរតកវប្បធម៌ធម្មជាតិផង ប្រកបដោយនិរន្តរភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ក្នុងច្បាប់នេះមានមាត្រាមួយដែលទាក់ទងខ្លាំងជាមួយនឹងកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងការការពារបរិស្ថានគឺត្រង់ជំពូកទី៥ ស្តីពីការការពារ និងអភិរក្សជលផល មាត្រា ២២ ដែលបានចែងថាៈ "*ហាមឃាត់ការចាក់ចោល ការបោះចោល ការបង្ហូរ ឬការបាចព្រោយទៅក្នុងដែននេសាទនូវកាកសំណល់រឹង ឬរាវ ឬសារធាតុពុល ដែលបានកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនៃព្រះរាជាណាចក្រកម្ពុជា និងអនុសញ្ញា ឬសន្ធិសញ្ញាអន្តរជាតិ ស្តីពីការបំពុលបរិស្ថាន ឬការប្រព្រឹត្តសកម្មភាពដែលធ្វើឱ្យពុល ឬការបង្កគ្រោះថ្នាក់ដល់វារីសត្វ និងវារីរុក្ខជាតិ*"។

## ២.៦ ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក

ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ព្រមទាំងស្រុង កាលពីថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៣ នីតិកាលទី២ ត្រូវបានសំរេចឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៦ នាថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៧។

ច្បាប់នេះមានគោលបំណង ជំរុញឱ្យមានការគ្រប់គ្រងធនធានទឹកប្រកបដោយប្រសិទ្ធិភាព និងនិរន្តរភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីសំរេចបាននូវការងារអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងសុខមាលភាពរបស់ប្រជាពលរដ្ឋ។ ច្បាប់នេះកំណត់ៈ

- សិទ្ធិ និងកាតព្វកិច្ចនៃអ្នកប្រើប្រាស់ទឹក
- គោលការណ៍គ្រឹះសំខាន់ៗសម្រាប់ការគ្រប់គ្រងធនធានទឹក

- ការចូលរួមរបស់សហគមន៍អ្នកប្រើប្រាស់ទឹក ក្នុងការអភិវឌ្ឍន៍ធនធានទឹកប្រកបដោយនិរន្តរភាព។

ច្បាប់នេះក៏បានបង្ហាញផងដែរនូវមាត្រាសំខាន់មួយចំនួន ដែលពាក់ព័ន្ធដល់កិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងការការពារបរិស្ថាន ដែលរួមមាន មាត្រា ៦ មាត្រា ៧ មាត្រា ១១ មាត្រា ១២ និងមាត្រា ២២។ ដែលមាត្រានីមួយៗ មានបង្ហាញជូនដោយសង្ខេបដូចខាងក្រោមៈ

**មាត្រា៦៖** ក្នុងការអនុវត្តន៍ច្បាប់គ្រប់គ្រងធនធានទឹក ក្រសួងធនធានទឹក និងឧតុនិយម ត្រូវកំណត់គោលនយោបាយគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍ ធនធានទឹក ស្របតាមតម្រូវការរបស់តំបន់នីមួយៗនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ក្នុងទិសដៅធានានិរន្តរភាពធនធានទឹក និងប្រសិទ្ធិភាពក្នុងការប្រើប្រាស់ទឹកដើម្បីជៀសវាងមហន្តរាយ និងវិវាទផ្សេងៗ។

**មាត្រា៧៖** ការសហការ និងការចូលរួមរបស់ស្ថាប័នពាក់ព័ន្ធផ្នែកឯកជន អ្នកទទួលផលប្រយោជន៍គ្រប់ប្រភេទ អង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិ នឹងត្រូវបានជំរុញដោយរាជរដ្ឋាភិបាលនៅក្នុងសកម្មភាពដែលទាក់ទងទៅនឹងការគ្រប់គ្រង ការវិនិយោគ ការធ្វើអាជីវកម្ម ការអភិរក្ស និងការអភិវឌ្ឍធនធានទឹក។

**មាត្រា១១៖** បុគ្គលគ្រប់រូបមានសិទ្ធិប្រើប្រាស់ធនធានទឹកក្នុងបរិមាណមួយមិនលើសពីសេចក្តីត្រូវការចាំបាច់ជាមូលដ្ឋានសម្រាប់ការហូបចុក បោកគក់ ងូត និងតម្រូវការផ្សេងទៀត រួមមានការចិញ្ចឹមសត្វ ការចិញ្ចឹមត្រី ការស្រោចស្រពសួនច្បារ និងដំណាំដោយចៀសវាងមិនឱ្យមានការប៉ះពាល់ដល់សិទ្ធិស្របច្បាប់របស់អ្នកដទៃ។ តម្រូវការខាងលើនេះមិនតម្រូវឱ្យសុំអាជ្ញាប័ណ្ណទឹកឡើយ។

**មាត្រា១២៖** ការបង្វែរទឹក ការយកទឹក ការប្រើប្រាស់ធនធានទឹក ក្នុងគោលបំណងកសិកម្ម ឬ ឧស្សាហកម្ម លើសពីកំរិតដែលមានចែងក្នុងមាត្រា ១១ និងសំណង់ការងារទឹកដែលពាក់ព័ន្ធ តម្រូវឱ្យមានការសុំអាជ្ញាប័ណ្ណទឹក ឬលិខិតអនុញ្ញាត។

**មាត្រា២២ ៖** រាល់ការបញ្ចេញចោល ការទុកចោល ឬការរក្សាទុកនូវសារធាតុពុល ដែលអាចធ្វើឱ្យប៉ះពាល់ដល់គុណភាពទឹក និងអាចបង្កគ្រោះថ្នាក់ដល់មនុស្ស សត្វ និងរុក្ខជាតិ ត្រូវតែសុំអាជ្ញាប័ណ្ណទឹក ឬការអនុញ្ញាត។ ប្រភេទសារធាតុពុល ដែលមានចែងខាងលើ និងស្តង់ដារបច្ចេកទេសនៃការបញ្ចេញទឹកសំណល់នឹងមានកំណត់ដោយអនុក្រឹត្យ។ រាល់កិច្ចដំណើរការក្នុងមាត្រានេះ ក្រសួងធនធានទឹក និងឧតុនិយមត្រូវពិគ្រោះយោបល់ជាមួយក្រសួងពាក់ព័ន្ធនានា។

## ២.៧ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ

ច្បាប់ស្តីពីតំបន់ការពារធម្មជាតិរបស់ក្រសួងបរិស្ថាន នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី ៣ និងព្រឹទ្ធសភាបានយល់ស្របតាម ទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយកាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៨ នាសម័យប្រជុំ

ពេញអង្គព្រឹទ្ធសភាលើកទី៤ នីតិកាលទី ២ ត្រូវបានសំរេចឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ នាថ្ងៃទី១៥ ខែ កុម្ភៈ ឆ្នាំ២០០៨។

**-មាត្រា ១១:** តំបន់ការពារធម្មជាតិនិមួយៗ បែងចែកចេញជាបួនតំបន់គ្រប់គ្រងគឺ

១.តំបន់ស្នូល: ជាតំបន់គ្រប់គ្រងដែលមានតំលៃខ្ពស់ សំរាប់ការអភិរក្សប្រភេទសត្វ រុក្ខជាតិ ដែលកម្រ ជិតផុតពូជទទួលរងគ្រោះថ្នាក់ គំរាមកំហែង និងមានប្រព័ន្ធអេកូឡូស៊ីផុយស្រួយ។

ការចេញ ចូលតំបន់នេះត្រូវហាមឃាត់ លើកលែងតែមន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិដែលមានភារកិច្ច និងអ្នកស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រធម្មជាតិក្នុងគោលបំណងការពារ និងអភិរក្សធនធានធម្មជាតិ ជីវៈចម្រុះ និងបរិស្ថាន ដែលត្រូវមានការអនុញ្ញាតជាមុនពីក្រសួងបរិស្ថាន លើកលែងតែក្នុងវិស័យសន្តិសុខ និងការពារជាតិ។

២.តំបន់អភិរក្ស: ជាតំបន់គ្រប់គ្រងស្ថិតនៅជាប់តំបន់ស្នូល ដែលមានតំលៃខាងការអភិរក្សធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី តំបន់ទីជំរាល និងតំបន់ដែលមានលក្ខណៈទេសភាពធម្មជាតិ។

ការចេញ ចូលតំបន់នេះត្រូវមានការអនុញ្ញាតជាមុនពីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិនៅនឹងកន្លែង លើកលែងតែមានការចាំបាច់ក្នុងវិស័យសន្តិសុខ និងការពារជាតិ។

ការប្រើប្រាស់អនុផលធនធានធម្មជាតិក្នុងតំបន់នេះ សំរាប់ជីវភាពសហគមន៍មូលដ្ឋាន និងជនជាតិដើម ដែលមិនប៉ះពាល់ខ្លាំងដល់ជីវៈចំរុះ ត្រូវស្ថិតក្រោមការត្រួតពិនិត្យយ៉ាងតឹងរឹងបំផុតរបស់រដ្ឋបាលការពារ និងអភិរក្សធម្មជាតិ។

៣.តំបន់ប្រើប្រាស់ដោយចីរភាព: ជាតំបន់គ្រប់គ្រងដែលមានតំលៃសេដ្ឋកិច្ចខ្ពស់បំរើដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ការគ្រប់គ្រង ការអភិរក្សតំបន់ការពារធម្មជាតិផ្ទាល់ និងចូលរួមលើកកំពស់ជីវភាពរស់នៅរបស់ប្រជាសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា អាចអនុញ្ញាតឱ្យមានការអភិវឌ្ឍន៍ និងការវិនិយោគនៅក្នុងតំបន់នេះ តាមរយៈការស្នើសុំរបស់ក្រសួងបរិស្ថាន ក្រោមពីមានការពិគ្រោះយោបល់ពីបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋានដី និងសហគមន៍មូលដ្ឋានដោយអនុលោមតាមច្បាប់ និងនីតិវិធីជាធរមាន។

៤.តំបន់សហគមន៍: ជាតំបន់គ្រប់គ្រងបំរើអោយការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចរបស់សហគមន៍ និងជនជាតិដើមភាគតិច ដែលមានសកម្មភាពស្រាប់ រួមមានលំនៅដ្ឋាន ស្រែ និងចំការ។

ការចេញប័ណ្ណដីធ្លី ឬការអនុញ្ញាតឱ្យប្រើប្រាស់ដីធ្លីនៅក្នុងតំបន់នេះត្រូវមានការបញ្ជាក់យល់ព្រមជាមុនពីក្រសួងបរិស្ថាន ដោយអនុលោមតាមច្បាប់ភូមិបាល។

តំបន់ការពារធម្មជាតិនេះ មិនគ្របដណ្តប់ទៅលើការកំណត់ និងការចាត់ចែងគ្រប់គ្រងរបស់អាជ្ញាធរអប្សរា និងអាជ្ញាធរដទៃទៀតដែលរាជរដ្ឋាភិបាលប្រគល់ភារកិច្ចអោយ។